

## តើកូនរបស់អ្នក៖

- កំពុងមានបញ្ហាធ្ងន់ធ្ងរនៅផ្ទះដែរឬទេ?
- អវត្តមានញឹកញាប់ ឬមានបញ្ហាធ្ងន់ធ្ងរនៅសាលាដែរឬទេ?
- រត់ចេញពីផ្ទះ ឬត្រូវបានកេងប្រវ័ញ្ចដែរឬទេ?

## មជ្ឈមណ្ឌលធនធានគ្រួសារ (FRC) អាចជួយបាន។

សេវា FRC គឺជាការស្ម័គ្រចិត្ត រក្សាការសម្ងាត់ ផ្តល់ជូននៅតាមសហគមន៍ និងអាចកែសម្រួលទៅតាមតម្រូវការគ្រួសាររបស់អ្នក។

សេវា FRC មានភាពងាយស្រួល ដោយកម្មវិធីមួយចំនួនផ្តល់ជូននៅពេលរសៀល និងនៅចុងសប្តាហ៍។



FRC-KH 4/24

# Family Resource Centers

ផ្តល់ជូននូវ កម្មវិធីថែទាំកូន ក្រុមគាំទ្រ សេវាវាយតម្លៃ និង ធនធានព័ត៌មាន និងបញ្ជូនបន្ត។





Family Resource Centers

www.frcma.org

# តើអ្វីទៅជា មជ្ឈមណ្ឌលធនធានគ្រួសារ (FRC)?

មជ្ឈមណ្ឌលធនធានគ្រួសារ (FRC) ជួយគ្រួសារ និងបុគ្គលទាំងឡាយនៅក្នុងការដោះស្រាយបញ្ហាប្រឈមពង្រឹងចំណងទាក់ទងជាមួយអ្នកដទៃ និងចូលរួមនៅក្នុងសហគមន៍របស់ខ្លួន។ FRC មានទីតាំងស្ថិតនៅក្នុងខោនធី Massachusetts ទាំង14។

# តើមជ្ឈមណ្ឌលធនធានគ្រួសារអាចធ្វើកិច្ចការអ្វីខ្លះ?

FRC ផ្តល់ជូននូវកម្មវិធីថែទាំកូន ក្រុមគាំទ្រ សេវាវាយតម្លៃ និងធនធានព័ត៌មាន និងបញ្ជូនបន្ត និងកម្មវិធីអប់រំសម្រាប់គ្រួសារដែលមានកូនស្ថិតនៅក្នុងក្រុមអាយុចាប់ពីពេលកើតរហូតដល់អាយុ 18 ឆ្នាំ។

FRC ក៏មានសេវាជាក់លាក់ផងដែរសម្រាប់គ្រួសារដែលមានកូនអវត្តមានជាញឹកញាប់ ឬមានបញ្ហាធ្ងន់ធ្ងរនៅសាលា មានបញ្ហាធ្ងន់ធ្ងរនៅផ្ទះ បានរត់ចេញពីផ្ទះ ឬត្រូវបានកេងប្រវ័ញ្ច។

FRCធ្វើការជាមួយឪពុកម្តាយ កុមារ មនុស្សជំទង់ ជីដូនជីតា អាណាព្យាបាល អ្នកថែទាំ ឬសមាជិកគ្រួសារ ឬសមាជិកសហគមន៍ផ្សេងទៀតដែលអាចពាក់ព័ន្ធជាមួយគ្រួសារ។

បុគ្គលិក FRC នឹងធ្វើការវាយតម្លៃតម្រូវការរបស់សមាជិកគ្រួសារ ណែនាំសេវា FRC និងអាចជួយឱ្យទទួលបានសេវាសហគមន៍ផ្សេងទៀត ប្រសិនបើចាំបាច់។

**សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងសេវាដែលមាននៅ FRC ណាមួយ សូមទាក់ទង FRC ដោយផ្ទាល់។ ព័ត៌មានទំនាក់ទំនងសម្រាប់ FRC អាចរកបានតាមរយៈវេបសាយត៍**
**www.frcma.org**

# មជ្ឈមណ្ឌលធនធានគ្រួសារ Massachusetts



### សេវាផ្តល់ជូនដោយមជ្ឈមណ្ឌលធនធានគ្រួសារ

- សិក្ខាសាលាជំនាញថែទាំកូន
- ក្រុមជួយខ្លួនឯង
- ក្រុមជីដូនជីតា
- សិក្ខាសាលាហិរញ្ញវត្ថុ
- សិក្ខាសាលាស្តីពីការគ្រប់គ្រងអារម្មណ៍ធុញថប់
- កម្មវិធីអប់រំ
- ព្រឹត្តការណ៍ និងសកម្មភាពគ្រួសារ
- ក្រុមលេងជាមួយកុមារ និងកម្មវិធីយុវជន
- សិល្បៈ វប្បធម៌ និងកម្មវិធីកីឡា
- ជួយឱ្យទទួលបានសេវាផ្សេងៗទៀត

### ទីតាំងមជ្ឈមណ្ឌលធនធានគ្រួសារ

- Amherst
- Athol
- Attleboro
- Barnstable/Hyannis
- Brockton
- Chelsea
- Everett
- Fall River
- Fitchburg
- Framingham
- Gardner
- Great Barrington
- Greenfield
- Holyoke
- Lawrence
- Lowell
- Lower Roxbury
- Lynn
- Nantucket
- New Bedford
- North Adams
- Oak Bluffs/Martha's Vineyard
- Pittsfield
- Plymouth
- Quincy
- Salem
- Southbridge
- Springfield
- Taunton
- Ware
- Westfield
- Worcester

**ទីតាំងនេះ នឹងបើកនៅឆ្នាំ 2024។**

- **Dorchester/Mattapan**

# របៀបទំនាក់ទំនង FRC

ទូរស័ព្ទ ឬអញ្ជើញមកកាន់ FRC ដែលអ្នកចង់ទំនាក់ទំនងតាមរយៈលេខទូរស័ព្ទ ឬអាសយដ្ឋានដែលមាននៅលើវេបសាយត៍ www.frcma.org។

អ្នកក៏អាចប្រើប្រាស់ Mass211 ដើម្បីទទួលព័ត៌មាន និងការបញ្ជូនបន្តមកកាន់ FRC ឬសេវាជាច្រើន

ផ្សេងៗទៀត។ Mass211 អាចទំនាក់ទំនងបានដោយចុចលេខ "211" ពីទូរស័ព្ទណាមួយនៅ Massachusetts រយៈពេល 24 ម៉ោងក្នុងមួយថ្ងៃ និងប្រាំពីរថ្ងៃក្នុងមួយសប្តាហ៍។ សេវាបកប្រែមានផ្តល់ជូនចំនួនជាង 140 ភាសាទៅតាមតម្រូវការចាំបាច់។

សម្រាប់ព័ត៌មានបន្ថែមពាក់ព័ន្ធនឹងសេវាដែលមាននៅ FRC ណាមួយ សូមទំនាក់ទំនង FRC ដោយផ្ទាល់។

Massachusetts 2-1-1 Get Connected. Get Answers.

**សូមមើលវេបសាយត៍របស់យើងដើម្បីស្វែងរកមជ្ឈមណ្ឌលធនធានគ្រួសារ**
**www.frcma.org**

